00610935

F8/1


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 09 / 2010
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA-MILART**
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម **Chandra Nihal JAYASINGHE**
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្តីសម្រេចស្តីពីការកំណត់ចរិតលក្ខណៈនៃបណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ចំពោះការសម្រេចពីឋានៈនៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង

---



អង្គជំនុំជម្រះតុលាការកំពូល
SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME
* E.C.C.C * C.E.T.C *

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ទី ស្រីនណា
Karim KHAN
Alain WERNER
Brianne McGONIGLE

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
Silke STUDZINSKY

**សហព្រះរាជអាជ្ញា៖**

ជា លាង
Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU

**ជនជាប់ចោទ៖**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ
កង ឫទ្ធារី



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME
E.C.C.C * C.E.T.C

00610937

F8/1

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រម" ("បណ្តឹងសាទុក្ខភ្លាមៗ")[1] ។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ដែលតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៥រូប"បុគ្គលប្រាំបួនរូប" បានដាក់បណ្តឹងសាទុក្ខភ្លាមៗ[2] ដោយអនុលោមទៅតាមវិធាន ១០៤.៤(ង) (វិសោធនកម្មលើកទី៣)។ យោងតាមវិធាន ១០៦(៣) និង(៤) (វិសោធនកម្មលើកទី ៣) នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់បណ្តឹងសាទុក្ខភ្លាមៗនេះសារឡើងវិញ ដោយភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិរបស់បុគ្គលទាំងអស់នេះ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បណ្តឹងសាទុក្ខភ្លាមៗសារជាថ្មីមកកាន់ក្រឡាបញ្ជីនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានបញ្ជូនបណ្តឹងសាទុក្ខភ្លាមៗនេះ ទៅផ្នែកគ្រប់គ្រងតុលាការរបស់អ.វ.ត.ក ដែលបានធ្វើសេចក្តីជូនដំណឹងនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។

## II. ផ្នែកសំអាងហេតុ

### ក. ច្បាប់ជាធរមាន

២. វិធានផ្ទៃក្នុង(វិសោធនកម្មលើកទី៣)ដែលពាក់ព័ន្ធ មានដូចខាងក្រោម៖

> សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបើកផ្លូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗដូចខាងក្រោម៖
>
> ...

---

[1] ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, F8 ("បណ្តឹងសាទុក្ខភ្លាមៗ")

[2] E188/10 *សេចក្តីសម្រេចស្តីពីការកំណត់ចរិតលក្ខណៈនៃបណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះការកំណត់ពីឋានៈនៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង* (លេខឯកសារ F8/1 ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០)

អង្គជំនុំជម្រះតុលាការកំពូល E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPREME

ង) សេចក្តីសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមវិធាន ២៣(៤)[3]។

## ខ. ការកំណត់ចរិតលក្ខណៈនៃបណ្តឹងសាទុក្ខឆ្លាមៗ

៣. អង្គជំនុំជម្រះតុលាការកំពូលរំលឹកឡើងវិញថា យោងតាមវិធាន១០៤(៤) (វិសោធនកម្មលើកទី ៣ និង ៦) ទស្សនៈទាននៃបណ្តឹងសាទុក្ខឆ្លាមៗ អាចអនុវត្តចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលដំណើរការនីតិវិធីជំនុំជម្រះក្តី ចំណែកឯទស្សនៈទាននៃ "បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម" អាចអនុវត្តចំពោះសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៤. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មិនបានប្រកាសឱ្យបានច្បាស់លាស់ស្តីពីការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គល០៥រូបនេះនៅក្នុង " សេចក្តីសម្រេច" នៃសាលក្រមរបស់ខ្លួននោះទេ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[4]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលអង្គសេចក្តីនៃការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី០៥រូបនេះ[5]នៅក្នុងផ្នែកសំអាងហេតុនៃសាលក្រមរបស់ខ្លួន។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទស្សនៈទាននៃ"បណ្តឹងសាទុក្ខឆ្លាមៗ" មិនអាចអនុវត្តចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការច្រានចោលការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន០៥រូបបានទេ។ យ៉ាងណាមិញ សេចក្តីសម្រេចនេះអាចធ្វើបណ្តឹងសាទុក្ខបាន ក្រោមរបបនីតិវិធីដែលអនុវត្តចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៥. ដើម្បីជាប្រយោជន៍នៃយុត្តធម៌ និងដោយផ្អែកតាមក្របខ័ណ្ឌនីតិវិធីនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក ដែលមានលក្ខណៈថ្មីហើយស្មុគស្មាញ អង្គជំនុំជម្រះតុលាការកំពូលសម្រេចកំណត់ចរិតលក្ខណៈ និងចាត់ទុកបណ្តឹងសាទុក្ខឆ្លាមៗនេះជាសេចក្តីជូនដំណឹងអំពី

---

[3] វិធានផ្ទៃក្នុង ១០៤.៤(ង) (វិសោធនកម្មលើកទី៣)

[4] ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

[5] សាលក្រមអង្គជំនុំជម្រះសាលាដំបូង, កថាខ័ណ្ឌ ៦៣៦, ៦៤៧-៦៤៩



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

បណ្ដឹងសាទុក្ខ និងជាសារណាបណ្ដឹងសាទុក្ខដែលបានដាក់ស្របតាមវិធាន១០៥(៣) វិធាន១០៦(២) ១០៦(៤)(៥) និងវិធាន១០៧(៤) (វិសោធនកម្មលើកទី ៦) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ រាល់ច្បាប់ទាំងឡាយដែលអាចអនុវត្តចំពោះការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណាបណ្ដឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ត្រូវយកមកអនុវត្ត។ សេចក្ដីសម្រេចនេះ មិនមានផលប៉ះពាល់ដល់ការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើអង្គសេចក្ដីនៃការសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំង០៩រូបនោះទេ។

៦. ហេតុដូច្នេះ ដើម្បីផ្ដល់អានុភាពឲ្យបានពេញលេញដល់បណ្ដឹងសាទុក្ខរបស់បុគ្គលទាំង០៩រូបនេះប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូល ស្នើសហមេធាវីដាក់នូវសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខបន្ថែម និងសារណាបណ្ដឹងសាទុក្ខបន្ថែមស្ដីអំពីអត្ថប្រយោជន៍រដ្ឋប្បវេណីរបស់បុគ្គលទាំង០៩រូបនេះ ប្រសិនបើខ្លួនមានបំណងធ្វើដូច្នោះមែន។

៧. យោងតាមវិធាន ២១(៤) និង៣៩(២)(វិសោធនកម្មលើកទី ៦) នៃវិធានផ្ទៃក្នុង និងមាត្រា ៨(២) នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខអ.វ.ត.ក[6] និងដោយពិចារណាលើស្ថានភាពនៃរឿងក្ដី អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខបន្ថែម និងសារណាបណ្ដឹងសាទុក្ខបន្ថែម ត្រូវដាក់ជូនក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងនៃសេចក្ដីសម្រេចនេះតទៅ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការកំណត់ពេលវេលានេះមានលក្ខណៈគ្រប់គ្រាន់ដើម្បីឲ្យបុគ្គលទាំង០៩រូបនេះ អនុវត្តសិទ្ធិប្ដឹងសាទុក្ខរបស់ខ្លួនបានពេញលេញស្របតាមវិធានផ្ទៃក្នុង។ ចំនួនទំព័រសរុបសម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខបន្ថែម និងសារណាបណ្ដឹងសាទុក្ខបន្ថែម មិនត្រូវឲ្យលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬ ភាសាបារាំង និង៦០ទំព័រជាភាសាខ្មែរឡើយ។

[6] អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៤
*សេចក្ដីសម្រេចស្ដីពីការកំណត់ចរិតលក្ខណៈនៃបណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះការកំណត់ពីឋានៈនៃដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង* (លេខឯកសារ F8/... ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០)

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

## III. ផ្នែកសម្រេចសេចក្តី

**យោងតាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆ័ន្ទៈ**

១. កំណត់ចរិតលក្ខណៈនៃបណ្តឹងសាទុក្ខភ្លាមៗនេះ ជាសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងជាសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

២. សហមេធាវីតំណាងបុគ្គលទាំង០៩រូបនេះ អាចដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខបន្ថែម និងសារណាបណ្តឹងសាទុក្ខបន្ថែម ក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងនៃសេចក្តីសម្រេចនេះតទៅ។ ចំនួនទំព័រសរុបសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខបន្ថែម និងសារណាបណ្តឹងសាទុក្ខបន្ថែម មិនត្រូវឲ្យលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬ ភាសាបារាំង និង៦០ទំព័រជាភាសាខ្មែរឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C * SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

**គង់ ស្រ៊ឹម**